## TriMet គោរពសិទ្ធិស៊ីវិល

TriMet ដំណើរការកម្មវិធីរបស់ខ្លួន ដោយមិនប្រកាន់ពីជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត សាសនា ភេទ ចំណង់ចំណូលចិត្តខាងផ្លូវភេទ ស្ថានភាពគ្រួសារ អាយុ ឬពិការភាព អនុលោមតាមច្បាប់ជាធរមាន ។

## ផ្នែក VI របស់TriMet ស្តីពីសេចក្តីថ្លែងការជាគោលការណ៍

ផ្នែក **VI** នៃច្បាប់សិទ្ធិស៊ីវិល ឆ្នាំ1964 ចែងថា :

"ពុំមានបុគ្គលណាម្នាក់ នៅក្នុងសហរដ្ឋអាមេរិក ត្រូវបានហាមឃាត់ មិនឱ្យចូលរួមទទួលបានផលប្រយោជន៍ ឬរងនូវការ រើសអើង នៅក្នុងកម្មវិធី ឬសកម្មភាពណាមួយ ដែលទទួលបានជំនួយហិរញ្ញវត្ថុសហព័ន្ធ ដោយសារជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត នោះឡើយ ។"

TriMet ប្តេជ្ញាចិត្តគោរព តាមលក្ខខណ្ឌនៃផ្នែក VI ក្នុងគ្រប់កម្មវិធី និងសកម្មភាពទាំងឡាយរបស់ខ្លួន ដែលផ្តល់ មូលនិធិដោយសហព័ន្ធ។ ដើម្បីស្នើសុំព័ត៌មានបន្ថែម អំពីផ្នែក VI របស់ TriMet ស្តីពីលក្ខខណ្ឌនៃការមិនរើសអើង សូម ទាក់ទងមកយើងខ្ញុំតាមរយៈទូរស័ព្ទលេខ 503-238-7433 (TTY 7-1-1) ឬផ្ញើសារទៅ hello@trimet.org ។

## ផ្នែក VI ស្តីពីការដាក់ពាក្យបណ្តឹង

បុគ្គលណាម្នាក់ ដែលយល់ថាគាត់ត្រូវបានគេធ្វើឱ្យមិនសប្បាយចិត្ត ដោយការប្រព្រឹត្តអំពើរើសអើងខុសច្បាប់ ក្រោម ផ្នែក VI អាចដាក់ពាក្យបណ្តឹងទៅ TriMet បាន។ ពាក្យបណ្តឹងនោះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយរៀបចំដាក់ទៅ TriMet ក្នុងរយៈពេល 180ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលមានការចោទប្រកាន់ អំពីការប្រព្រឹត្តអំពើរើសអើងកើតឡើង ។ ដើម្បីទទួលបានព័ត៌មាន អំពីរបៀបដាក់ពាក្យបណ្តឹង សូមទាក់ទង TriMet តាមរយៈវិធីណាមួយ ក្នុងចំណោមវិធីនានា ខាងក្រោមនេះ ។

TriMet
Director, Diversity and Transit Equity
1800 SW 1st Avenue, Suite 300
Portland, OR 97201

ទូរស័ព្ទ : 503-962-2217

ទូរសារ : 503-962-6469

**អ៊ីមែល** : hello@trimet.org

អ្នកប្រហែលជាអាចដាក់ពាក្យបណ្តឹងផ្នែករដ្ឋបាលឆ្លងកាត់សហព័ន្ធ (Federal Transit Administration)បាន ដោយផ្ញើទៅក្រសួងសិទ្ធិស៊ីវិល តាមអាស័យដ្ឋាន Office of Civil Rights, Attention: Title VI Program Coordinator, East Building, 5th Floor-TCR, 1200 New Jersey Ave., SE, Washington, D.C. 20590 ។

# នីតិវិធីបណ្តឹងសិទ្ធិពលរដ្ឋ

ជនណាក៏ដោយដែលជឿជាក់ថា គាត់ត្រូវបានធ្វើឲ្យរងទុក្ខដោយការអនុវត្តបែបរើសអើង ដោយខុសច្បាប់ផ្អែកលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ សាសនា យេនឌ័រ ភេទ ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ឬអាយុដោយ TriMet អាចនឹងដាក់ពាក្យបណ្តឹងបានដោយបំពេញ និងដាក់ទម្រង់បែបបទបណ្តឹងសិទ្ធិពលរដ្ឋរបស់ TriMet។

TriMet ស៊ើបអង្កេតបណ្តឹងដែលទទួលបានមិនលើសពី 180 ថ្ងៃក្រោយពីឧបទ្ទវហេតុដែលបានរៀបរាប់ខាងលើនេះ។ TriMet នឹងរត់ការបណ្តឹងដែលបានបំពេញសព្វគ្រប់។ ពេលបានទទួលបណ្តឹងដែលបានបំពេញសព្វគ្រប់នោះហើយ TriMet នឹងពិនិត្យមើលវាឡើងវិញ ដើម្បីកំណត់ថាតើ TriMet មានយុត្តាធិការដែរឬទេ។ អ្នកដាក់ពាក្យបណ្តឹងនឹងទទួលបានលិខិតទទួលស្គាល់ ដែលជម្រាបគាត់ថាតើបណ្តឹងនឹងត្រូវបានស៊ើបអង្កេតដោយ TriMet ដែរឬទេ។
TriMet ជាទូទៅនឹងបញ្ចប់ការស៊ើបអង្កេតក្នុងរង្វង់ 90 ថ្ងៃគិតចាប់ថ្ងៃទទួលបានទម្រង់បែបបទបណ្តឹងដែលបានបំពេញ។ ប្រសិនបើត្រូវការព័ត៌មានបន្ថែម ដើម្បីដោះស្រាយរឿងក្តីនេះ TriMet អាចនឹងទាក់ទងអ្នកដាក់បណ្តឹង។ លុះត្រាតែរយៈពេលវែងជាងនេះត្រូវបានបញ្ជាក់ដោយ TriMet បើមិនដូច្នោះទេ អ្នកដាក់បណ្តឹងនឹងមានពេលដប់ (10) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៅលើលិខិត ដើម្បីផ្ញើព័ត៌មានដែលបានស្នើសុំទៅកាន់អ្នកស៊ើបអង្កេតរបស់ TriMet ដែលត្រូវបានចាត់តាំងឲ្យដោះស្រាយរឿងក្តីនេះ។
ប្រសិនបើអ្នកស៊ើបអង្កេតរបស់ TriMet មិនត្រូវបានទាក់ទងដោយអ្នកដាក់ពាក្យបណ្តឹង ឬមិនទទួលបានព័ត៌មានបន្ថែមក្នុងរង្វង់ពេលដែល បានទាមទារទេ នោះ TriMet អាចនឹងបិទរឿងក្តីនេះជាលក្ខណៈរដ្ឋបាល។ រឿងក្តីមួយអាចនឹងត្រូវបានបិទជាលក្ខណៈរដ្ឋបាលផងដែរ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងលែងចង់បន្តរឿងក្តីរបស់ពួកគេ។

ក្រោយការស៊ើបអង្កេតចប់សព្វគ្រប់ហើយ TriMet នឹងចេញលិខិតជូនទៅកាន់អ្នកដាក់ពាក្យបណ្តឹងដែលសង្ខេបនូវលទ្ធផលនៃការស៊ើបអង្កេតដោយថ្លែងពីលទ្ធផលរកឃើញ និងផ្តល់ការណែនាំអំពីសកម្មភាពកែតម្រូវណាមួយដែលត្រូវអនុវត្តជាលទ្ធផលនៃការស៊ើបអង្កេត។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងមិនយល់ស្របជាមួយសេចក្តីសម្រេចចុងក្រោយរបស់ TriMet ទេ អ្នកដាក់ពាក្យបណ្តឹងអាចនឹងស្នើសុំការពិចារណាឡើងវិញដោយដាក់សំណើសុំជាលាយលក្ខណ៍អក្សរទៅកាន់អ្នកគ្រប់គ្រងទូទៅរបស់ TriMet ក្នុងរង្វង់ប្រាំពីរ (7) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃលិខិតរបស់ TriMe ដែលថ្លែងដោយភាពជាក់លាក់នូវមូលដ្ឋានគ្រឹះសម្រាប់ការពិចារណាឡើងវិញ។ អ្នកគ្រប់គ្រងទូទៅនឹងជូនដំណឹងអ្នកដាក់បណ្តឹងនូវការសម្រេចចិត្តរបស់គាត់ថាតើត្រូវទទួលយក ឬបដិសេធសំណើសុំការពិចារណាឡើងវិញក្នុងរង្វង់ 10 ថ្ងៃដែរឬទេ។ ក្នុងករណីដែលការពិចារណាឡើងវិញត្រូវបានផ្តល់ជូន នោះអ្នកគ្រប់គ្រងទូទៅនឹងចេញលិខិតកំណត់ទៅកាន់អ្នកដាក់ពាក្យបណ្តឹងនៅពេលបញ្ចប់ការពិនិត្យលើការពិចារណាឡើងវិញរួច។

# ក្រុមហ៊ុនដឹកជញ្ជូននៅក្នុងតំបន់ចំនួនបីនៃរដ្ឋអូរីហ្គន
# Tri-County Metropolitan Transportation District of Oregon (TriMet)

1800 SW 1st Ave., Suite 300 503.962.2213
Portland, OR 97201 trimet.org

## ផ្នែក VI ស្តីពីបែបបទនៃពាក្យបណ្តឹង*

ផ្នែក VI នៃច្បាប់សិទ្ធិស៊ីវិល ឆ្នាំ1964 ចែងថា " ពុំមានបុគ្គលណាម្នាក់ នៅក្នុងសហរដ្ឋអាមេរិក ត្រូវបានហាមឃាត់មិនឱ្យចូលរួមទទួលបានផលប្រយោជន៍ ឬរងនូវការរើសអើង នៅក្នុងកម្មវិធី ឬសកម្មភាពណាមួយ ដែលទទួលបានជំនួយហិរញ្ញវត្ថុសហព័ន្ធ ដោយសារជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត បានឡើយ ។"

ព័ត៌មានខាងក្រោមនេះ មានសារៈសំខាន់ ក្នុងការជួយដល់ដំណើរការដាក់ពាក្យបណ្តឹងរបស់លោកអ្នក ។

ប្រសិនបើលោកអ្នកត្រូវការជំនួយ ក្នុងការបំពេញបែបបទនេះ ឬត្រូវការព័ត៌មានជាជម្រើស ក្នុងទម្រង់ផ្សេងៗ ទៀត សូមទាក់ទងមកយើងខ្ញុំ ។

សូមបំពេញ និងប្រគល់បែបបទនេះ ទៅប្រធានផ្នែកភាពសម្បូរបែប និងសមភាពក្នុងការធ្វើដំណើរ TriMet តាមរយៈអាសយដ្ឋាន 1800 SW 1st Ave., Suite 300, Portland, OR 97201 ។

1. ឈ្មោះអ្នកដាក់ពាក្យបណ្តឹង : ______________________________

2. អាសយដ្ឋាន :______________________________

3. ទីក្រុង :______________________ រដ្ឋ :__________ លេខកូដប្រទេស :__________

4. លេខទូរស័ព្ទ (នៅផ្ទះ) :__________________ (ការងារ) :__________________
អាសយដ្ឋានអ៊ីមែល: ______________________________

5. តើអ្នកដាក់ពាក្យបណ្តឹងនេះ ជាខ្លួនលោកអ្នកផ្ទាល់មែនដែរឬទេ ? _______ ។ប្រសិនពុំមែនទេ សូមមេត្តាផ្តល់ឈ្មោះ និងប្រាប់ពីទំនាក់ទំនងរបស់បុគ្គលដែលអ្នកដាក់ពាក្យបណ្តឹងឱ្យ : ______________________________.
សូមប្រាប់ពីមូលហេតុដែលអ្នកដាក់ពាក្យបណ្តឹងឱ្យភាគីទីបី :
______________________________
______________________________
សូមបញ្ជាក់ថា លោកអ្នកបានទទួលការអនុញ្ញាតពីភាគី ដែលត្រូវបានគេធ្វើឱ្យមិនសប្បាយចិត្តប្រសិនបើលោកអ្នកដាក់ពាក្យបណ្តឹងឱ្យភាគីទីបីនោះ ។ ______________________________

6. តើចំណុចណាមួយខាងក្រោមនេះ ពណ៌នាបានល្អបំផុត ពីមូលហេតុដែលធ្វើឱ្យលោកអ្នកយល់ថា មានការរើសអើងកើតឡើង ? តើវាកើតឡើង ដោយសារ (សូមជ្រើសរើសប្រអប់ណាមួយដែលត្រឹមត្រូវ) :

ក. ជាតិសាសន៍ : ☐
ខ. ពណ៌សម្បុរ : ☐
គ. ដើមកំណើត : ☐

7. តើការរើសអើង កើតមានឡើងនៅពេលណា ?______________________________

8. សូមពិពណ៌នាពីការរើសអើង ដែលរងការចោទប្រកាន់ ដោយសំដីផ្ទាល់របស់លោកអ្នក ។ សូមប្រាប់ពីរឿងរ៉ាវ ដែលបានកើតឡើង និងគោលការណ៍ កម្មវិធី សកម្មភាព ឬបុគ្គលដែលលោកអ្នកយល់ថា មានការរើសអើង ។

______________________________
______________________________
______________________________
______________________________
______________________________
______________________________

9. តើលោកអ្នកធ្លាប់បានដាក់ពាក្យបណ្ដឹងនេះ ទៅភ្នាក់ងារតំបន់ សហព័ន្ធ ឬរដ្ឋ ឬទៅតុលាការសហព័ន្ធ ឬរដ្ឋ ដែរឬទេ?

ធ្លាប់ : ☐ ពុំធ្លាប់ទេ : ☐

បើធ្លាប់ សូមជ្រើសរើសប្រអប់ណាមួយដែលត្រឹមត្រូវ :

ភ្នាក់ងារសហព័ន្ធ ☐ តុលាការសហព័ន្ធ ☐ ភ្នាក់ងាររដ្ឋ ☐
តុលាការរដ្ឋ ☐ ភ្នាក់ងារតំបន់ ☐

10. សូមផ្ដល់ព័ត៌មាន អំពីបុគ្គលសម្រាប់ទំនាក់ទំនងនៅភ្នាក់ងារ /តុលាការ ដែលជាកន្លែងដាក់ពាក្យបណ្ដឹង ។

ឈ្មោះ :______________________________

អាសយដ្ឋាន :______________________________

ទីក្រុង :______________ រដ្ឋ : ________ លេខកូដប្រទេស :______________

លេខទូរស័ព្ទ :______________________________

11. សូមចុះហត្ថលេខា នៅខាងក្រោមនេះ ។ លោកអ្នកអាចភ្ជាប់មកជាមួយ នូវឯកសារជាលាយលក្ខណ៍អក្សរ ឬព័ត៌មាន ផ្សេងៗ ដែលយល់ថាពាក់ព័ន្ធនឹងពាក្យបណ្ដឹងរបស់លោកអ្នក ។

______________________________ ______________________
ហត្ថលេខារបស់អ្នកដាក់ពាក្យបណ្ដឹង កាលបរិច្ឆេទ